# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍

លេខ ០៩៦ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ១១ ឆ្នាំ២០១១

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
និង យុវនីតិសម្បទា
ចូល
នា-រដ្ឋបាល និង បុគ្គលិក
លេខ 2435 នាយក
ថ្ងៃទី 04 ខែ 11 ឆ្នាំ 2011
បញ្ជូន..........

## ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារដើម្បីកុមាររបស់ក្រសួងទេសចរណ៍

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ 227
ថ្ងៃទី 07.11.11 ម៉ោង
បញ្ជូន..........

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីទេសចរណ៍
- បានឃើញអនុសញ្ញា ស្តីពី សិទ្ធិកុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិ កម្ពុជាដើម្បីកុមារ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតម្រូវការចាំបាច់នៃការអភិវឌ្ឍវិស័យសុខុមាលភាពកុមារ ។

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារដើម្បីកុមាររបស់ក្រសួងទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ហោ សារុន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ប្រធាន |
| ២- | លោក | **កើត ពុទ្ធវី** | អគ្គនាយករងទេសចរណ៍ | អនុប្រធាន |
| ៣- | លោកស្រី | **ចាយ សុវណ្ណនី** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិកអចិន្ត្រៃយ៍ |
| ៤- | លោក | **សំ សេង** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |

៥- លោក **សួន ម៉ារឌី** អនុប្រធាននាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍ សមាជិក

៦- លោកស្រី **គីម សុវណ្ណា** អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ សមាជិក

៧- លោក **ពុទ្ធា សោភ័ណ្ឌារ៉ា** នាយការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល លេខាធិការ

៨- កញ្ញា **ហួតនន់ សុខាវណ្ណណែត** នាយការិយាល័យ នាយកដ្ឋានបណ្តុះបណ្តាល សមាជិក

៩- លោកស្រី **ដោក ស៊ីណារ៉ា** នាយការិយាល័យ នាយកដ្ឋានឧស្សាហកម្ម សមាជិក

**ប្រការ ២** : ក្រុមការងារដើម្បីកុមារនៅក្នុងក្រសួងទេសចរណ៍មានតួនាទី និងភារកិច្ចដូចតទៅ :

- ពិគ្រោះយោបល់សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហាកុមារនៅក្នុងក្រសួងទេសចរណ៍
- ពិនិត្យ តាមដាន វាយតម្លៃ លើការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមាររបស់ក្រសួង និងលើកសំណើជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ **"ក.ជ.ក"** និងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារនៅក្នុងក្រសួង
- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញា ស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋាន គតិយុត្តិនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ **"ក.ជ.ក"** ពាក់ព័ន្ធ នឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព
- រៀបចំផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍របស់កុមារសម្រាប់ក្រសួង មានជាអាទិ៍ ការគោរព និងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងប្រឆាំង នឹងការជួញដូរគ្រឿងញៀន
- បញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីការងាររបស់ក្រសួង
- ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដែលមានគម្រោង ការងារពាក់ព័ន្ធនឹងកុមារនៅក្នុងក្រសួង ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ
- រៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា
- ចាត់ចែងអនុវត្តរាល់គោលការណ៍ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ **"ក.ជ.ក"**
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **"ក.ជ.ក"** ប្រគល់ជូន
- ធ្វើការបូកសរុបរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តសកម្មភាពការងាររៀងរាល់ខែ ត្រីមាស ឆមាស ០៩ខែ និងឆ្នាំ ព្រមទាំងលើកសំណូមពរចាំបាច់ជូនឯកឧត្តមរដ្ឋមន្ត្រីពិនិត្យ និងសម្រេច មុននឹងរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ។

**ប្រការ ៣** : ក្រុមការងារដើម្បីកុមារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤** : គណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ ។

**ប្រការ ៥** : ក្រុមការងារដើម្បីកុមាររបស់ក្រសួងទេសចរណ៍មានលេខាធិការដ្ឋានជាសេនាធិការ ដែលមានសមាសភាព:

១- លោកស្រី **ចាយ សុវណ្ណឌី** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល ប្រធាន

២- លោកស្រី **គីម សុវណ្ណា** អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ អនុប្រធាន

| | | | |
|---|---|---|---|
| ៣- | លោក | **ពុទ្រា សោភ័ណ្ណរ៉ា** | នាយការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិកអចិន្ត្រៃយ៍ |
| ៤- | កញ្ញា | **ហួតនន់ សុខាវណ្ណណែត** | នាយការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាល លេខាកត់ត្រា |
| ៥- | កញ្ញា | **ទ្រី សុខឡា** | នាយរងការិល័យរដ្ឋបាល និងកិច្ចការទូទៅ សមាជិក |
| ៦- | លោក | **ពៅ សំណាង** | នាយរងការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក |
| ៧- | លោក | **យឹម ប៊ុនធឿន** | នាយរងការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក |
| ៨- | អ្នកស្រី | **ឡាយ កន្និកា** | មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍ សមាជិក |
| ៩- | កញ្ញា | **ផាង និតហ៊ៀរី** | មន្ត្រីនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ សមាជិក |
| ១០- | អ្នកស្រី | **ប៊ុន បូនីណា** | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ សមាជិក |
| ១១- | កញ្ញា | **ស៊ា សុធីតា** | មន្ត្រីនាយកដ្ឋានឧស្សាហកម្មទេសចរណ៍ សមាជិក |

**ប្រការ ៦:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាជាតិដើម្បីកុមារ
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ